# ការប្រជុំជាមួយក្រុមជនជាតិភាគតិចនៅកម្ពុជា
# យល់ដឹងពីអំពើប្រល័យពូជសាសន៍ : ការពិត, ការចងចាំ និង យុត្តិធម៌
# ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

នៅខែកញ្ញា ឆ្នាំ២០១០ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម៤នាក់ត្រូវបានចោទប្រកាន់ជាផ្លូវការដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពីបទ ប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានទៅលើច្បាប់កម្ពុជា ។ ការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ជាពិសេស បានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំង ។ ទោះបីជាប្រជាពលរដ្ឋកម្ពុជាប្រើពាក្យ “ប្រល័យពូជសាសន៍” ជាយូរមកហើយ ដើម្បីពិពណ៌នាការសម្លាប់ដោយរបបខ្មែរក្រហម ប៉ុន្តែប្រជាពលរដ្ឋកម្ពុជាមិនបានយល់ស្របទៅលើអត្ថន័យរបស់ពាក្យនោះ ឬថាប្រជាពលរដ្ឋកម្ពុជាមានការយល់ដឹងច្បាស់លាស់អំពីនិយមន័យរបស់ពាក្យនេះតាមផ្លូវច្បាប់និងប្រវត្តិសាស្ត្រយ៉ាងណាទេ ។

ដោយទទួលស្គាល់ការយល់ច្រឡំយ៉ាងខ្លាំងពីបទចោទលើអំពើប្រល័យពូជសាសន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំការប្រជុំធំៗពីរជាមួយក្រុមជនជាតិភាគតិចនៅកម្ពុជា ។ ការប្រជុំលើកទី១ធ្វើឡើងនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដោយបង្ហាញជូនអ្នកចូលរួមពីការប្រើប្រាស់ពាក្យប្រល័យពូជសាសន៍និងប្រវត្តិនៃពាក្យ ដោយស្របតាមច្បាប់ក្នុងស្រុកនិងអន្តរជាតិ ក៏ដូចជាវិទ្យាសាស្ត្រសង្គមនិងអក្សរសាស្ត្រខ្មែរ ។ ការប្រជុំក៏បញ្ចូលសកម្មភាពមួយចំនួន ដើម្បីផ្តល់កិត្តិយសដល់ជនរងគ្រោះ និងជំរុញឲ្យមានការសន្ទនាជុំវិញប្រធានបទទាំងឡាយដែលបានលើកឡើង ។

បន្ថែមទៅលើការបកស្រាយពាក្យប្រល័យពូជសាសន៍និងជួយឲ្យប្រជាពលរដ្ឋចូលរួមក្នុងដំណើររបស់តុលាការ ការប្រជុំនេះមានគោលបំណងដើម្បីរៀបចំឲ្យប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាន់តែពេញលេញ តាមរយៈការប្រមូលសាច់រឿងរបស់អ្នកចូលរួម ការពិភាក្សា និងការចូលរួមក្នុងដំណើរការស្វែងរកការពិត ។

## ១. អ្នកចូលរួម

តំណាងក្រុមជនជាតិភាគតិចប្រហែល២០០នាក់ បានចូលរួមក្នុងការប្រជុំថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១០ ។ អ្នកចូលរួមទាំងនេះរួមមាន ជនជាតិចាម (ស្ត្រីនិងអ្នកដឹកនាំសហគមន៍) សមាជិកខ្មែរកម្ពុជាក្រោម សមាជិកក្រុមជនជាតិភាគតិចវៀតណាម ព្រះសង្ឃ បព្វជិត និងសមាជិកក្រុមជនជាតិភាគតិចតំបន់ភ្នំ ។

ក្រុមជនជាតិភាគតិចទាំងនេះបានរងគ្រោះយ៉ាងធ្ងន់ធ្ងរក្រោមរបបខ្មែរក្រហម ។ ជនជាតិចាមរវាង ១០០,០០០-៤០០,០០០នាក់ និងជនជាតិភាគតិចវៀតណាមប្រហែល៣០០,០០០នាក់ បានស្លាប់បាត់បង់ជីវិតដោយសារគោលនយោបាយខ្មែរក្រហម ។ ខ្មែរកម្ពុជាក្រោមជាច្រើនត្រូវបានចោទប្រកាន់ថា មាន "ក្បាលយួនខ្លួនខ្មែរ" ហើយត្រូវបានជម្លៀសចេញ ធ្វើទារុណកម្ម និងសម្លាប់ ។ ព្រះសង្ឃត្រូវបានបង្ខំឲ្យសឹក និងធ្វើការនៅតាមវាលស្រែ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាអញ្ជើញតំណាងក្រុមជនជាតិភាគតិចមកចូលរួមការប្រជុំរួមជាមួយគ្នា ។ ការប្រជុំតម្រូវឲ្យមានការរៀបចំទុកជាមុននិងការសម្របសម្រួលយ៉ាងខ្លាំង ហើយមជ្ឈមណ្ឌលឯកសារ កម្ពុជាបានរៀបចំការដឹកជញ្ជូន កន្លែងស្នាក់នៅ ម្ហូបអាហារ និងសោហ៊ុយធ្វើដំណើរពីលំនៅដ្ឋានរបស់អ្នកចូលរួមមកទីក្រុងភ្នំពេញ ។

## ២.កម្មវិធីពេលព្រឹក ៖ ប្រល័យពូជសាសន៍ក្នុងបរិបទច្បាប់និងវិប្បធម៌

នៅពេលដែលអ្នកចូលរួម វាគ្មិន អ្នកសារព័ត៌មាន និងអ្នកអង្កេត បានជួបជុំគ្នានៅក្នុងសាលប្រជុំ នៅម៉ោង៨ព្រឹក ថ្ងៃទី២៥ កញ្ញា សូ ហ្វារីណា ដែលជាប្រធានគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំក្នុងសហគមន៍ចាមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បើកកម្មវិធីប្រជុំជាមួយសុន្ទរកថាស្វាគមន៍ និងសេចក្តីសង្ខេបកម្មវិធីប្រជុំ ។

បន្ទាប់មក កញ្ញា ហ្វារីណា បានស្នើឲ្យអ្នកចូលរួមបំពេញតារាងស្ទង់មតិដើម្បីស្ទាបស្ទង់មើលការយល់ដឹងនិងទស្សនៈវិស័យទៅលើអំពើប្រល័យពូជសាសន៍ ។ សំណួរនៅក្នុងតារាងស្ទង់មតិរួមមាន សមាជិកក្រុម គ្រួសារដែលបានបាត់បង់ក្រោមរបបខ្មែរក្រហម, មុនដំបូងអ្នកចូលរួមឮពាក្យ "ប្រល័យពូជសាសន៍", ហេតុផលដែលសាលាក្តីមិនធ្វើការចោទប្រកាន់មេដឹកនាំខ្មែរក្រហមក្នុងការ

ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅលើក្រុមជនជាតិភាគតិចផ្សេង ក្រៅពីជនជាតិភាគតិចចាម និង ជនជាតិភាគតិចវៀតណាម ។

នៅពេលដែលអ្នកចូលរួមទទួលបានក្រដាសស្ទង់មតិ សាលប្រជុំមានសភាពស្ងាត់ជ្រងំមួយស្របក់ ដោយសារអ្នកចូលរួមកំពុងតែគិតពីចម្លើយយ៉ាងប្រុងប្រយ័ត្ន ។ មានតែសំឡេងខ្សឹបៗរបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានជួយដល់អ្នកចូលរួមដែលមិនចេះសរសេរ ។ កញ្ញា ហ្វារីណា បាន ពន្យល់សំណួរទាំងឡាយ ហើយទុកពេលវេលាឲ្យអ្នកចូលរួមបំពេញ ។ បន្ទាប់ពីផ្តល់ពេលវេលាអស់មួយស្របក់មក កញ្ញា ហ្វារីណា បានសុំឲ្យអ្នកចូលរួមប្រគល់តារាងស្ទង់មតិមកឲ្យក្រុមការងារ ។ បន្ទាប់មកទៀត កញ្ញា ហ្វារីណា បានជម្រាបឈ្មោះវាគ្មិនកិត្តិយសដែលនឹងធ្វើបទបង្ហាញនៅក្នុងការប្រជុំ ដែលវាគ្មិនដំបូងគឺលោក អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ក) និយមន័យប្រល័យពូជសាសន៍តាមផ្លូវច្បាប់និងប្រវត្តិអនុសញ្ញាការពារអំពើប្រល័យពូជសាសន៍ ដោយលោក អេនឌ្រូ ខេលី និង តំណាងរបស់ លោកជំទាវ ជា លាង

លោក អេនឌ្រូ ចាប់ផ្តើមសុន្ទរកថារបស់គាត់ដោយការទទួលស្គាល់ថា អំពើប្រល័យពូជសាសន៍គឺជាពាក្យពិបាកកំណត់ ហើយមេធាវីជាច្រើនមានការលំបាកក្នុងការស្វែងរកការពន្យល់ពាក្យនេះតាមផ្លូវច្បាប់ឲ្យបានសមស្រប ។ ទោះបីយ៉ាងណាក៏ដោយ មុនពេលចូលដល់ការពិភាក្សាពីការវិវត្តន៍នៃនិយមន័យនៃពាក្យនេះ គាត់យកពេលខ្លះពិភាក្សាបទចោទប្រកាន់លើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ គាត់បានផ្តល់យោបល់ដល់អ្នកចូលរួមមិនឲ្យសង្កត់ធ្ងន់ហួសហេតុពេក ទៅលើការចោទពីបទប្រល័យពូជសាសន៍ នៅពេលគិតទៅដល់បទចោទទូទៅផ្សេងៗទៀត ទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ខណៈពេលដែល អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្នុងច្បាប់អន្តរជាតិ មានឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាច្រើនទៀត នៅក្រោមច្បាប់ជាតិនិងអន្តរជាតិដែលមេដឹកនាំទាំង៤នាក់ត្រូវបានចោទប្រកាន់ ។

បទបង្ហាញទូទៅរបស់លោក អេនឌ្រូ បានចាប់ផ្តើមពីការពិពណ៌នាហេតុការណ៍ទាំងឡាយដែលនាំឲ្យកើតមានច្បាប់និងបញ្ញត្តិប្រល័យពូជសាសន៍ ការពិភាក្សាពីក្របខណ្ឌច្បាប់បច្ចុប្បន្ន ការអនុវត្តច្បាប់លើអង្គហេតុក្នុងសំណុំរឿង០០២ ការឲ្យយោបល់ជាថ្មីម្តងទៀតដល់អ្នកចូលរួម ដោយមិនឲ្យគិត

ថាមានតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាឧក្រិដ្ឋកម្មយង់ឃ្នងជាងគេ នៅក្នុងបទចោទទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។

អ្នកចូលរួមប្រុងប្រៀបស្ដាប់ដោយមានការប្រុងប្រយ័ត្ន ជាពិសេសនៅពេលដែលលោក ខេលី បកស្រាយសំណុំរឿង០០២ ។ គាត់បានប្រាប់ថា ការិយាល័យរបស់គាត់កំពុងតែធ្វើការផារឈានទៅមុខ ចេញពីការបង្ហាញថា ខ្មែរក្រហមបានជម្លៀកនិងសម្លាប់ព្រះសង្ឃ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយ៉ាងច្បាស់ក្រឡែត រហូតដល់ការបង្ហាញថា ខ្មែរក្រហមបំបែកនិងសម្លាប់ជនជាតិចាមដែលនេះជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងប្រល័យពូជសាសន៍ ។ ក្នុងការគោរពដល់ជនជាតិភាគតិចវៀតណាម លោក អេនឌ្រូ បានបញ្ជាក់ថា ភ័ស្តុតាងនៃការបញ្ជូនចេញពីភូមិភាគបូព៌ា ភូមិភាគកណ្ដាល និង ភូមិភាគនិរតី គួរតែអាចប្រើដើម្បីបង្ហាញពីបទចោទពីអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម ។ អ្នកចូលរួមរក្សាភាពស្ងប់ស្ងាត់ ជាសញ្ញានៃការទទួលយកនូវអ្វីដែលសហព្រះរាជអាជ្ញាបានរៀបរាប់ ។

លោក អេនឌ្រូ បញ្ចប់សុន្ទរកថារបស់គាត់ ហើយប្រគល់នាទីឲ្យទៅលោក ចាន់ តារាវស្មី សហព្រះរាជអាជ្ញារងកម្ពុជា ។ លោក តារាវស្មី បានថ្លែងអំណរគុណដល់លោក អេនឌ្រូ ចំពោះការបកស្រាយយ៉ាងក្បោះក្បាយ ហើយក៏បន្តសង្កត់ធ្ងន់យ៉ាងស៊ីជម្រៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ គាត់កត់សម្គាល់ថា ខ្មែរក្រហម «បំផ្លាញ» ចំនួនប្រជាជនតាមមធ្យោបាយជាច្រើន ហើយអស់រយៈកាលជាច្រើនឆ្នាំ បន្ទាប់ពីរបបនេះត្រូវបានផ្ដួលរំលំ ដោយធ្វើឲ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសនិងពន្យឺតការអភិវឌ្ឍន៍យ៉ាងមហិមា ។ អ្នកចូលរួមយល់ស្របនឹងការលើកឡើងនេះដោយសំឡេងខ្សឹបៗ ហើយក្រោយមកក៏ទះដៃយ៉ាងខ្លាំងបន្ទាប់ពីគាត់បញ្ចប់សុន្ទរកថា ។

កញ្ញា ហ្វារីណា បានថ្លែងអំណរគុណដល់វាគ្មិនទាំងពីររូប ហើយប្រកាសប្រាប់អ្នក ចូលរួមថាពួកគាត់អាចមានឱកាសសួរសំណួរទៅកាន់សហព្រះរាជអាជ្ញាទាំងពីរ ប៉ុន្តែជាដំបូងទទួល ស្គាល់ថាទស្សនៈច្បាប់មានភាពស្មុគស្មាញនិងលំបាកយល់បន្តិច ហើយសុំឲ្យអ្នកចូលរួមប្រើប្រាស់ ឱកាសនេះដើម្បីសួរនូវអ្វីដែលមិនទាន់យល់ ។ អ្នកចូលរួម២-៣នាក់បានសួរសំណួរ រួមទាំងបុរសម្នាក់ដែលចង់ដឹងអំពីទោសទណ្ឌដែលខ្ពស់បំផុតសម្រាប់អ្នកដែលជាប់ទោស ហើយម្នាក់ទៀតសួរថាហេតុអ្វីបានជាប្រទេសដែលរួមចំណែកឲ្យមានជម្លោះនៅកម្ពុជាមិនត្រូវបានកាត់ទោស ។

សម្រាប់សំណួរចុងក្រោយ លោក ខេលី ឆ្លើយថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានយុត្តាធិការជំនុំជម្រះតែបុគ្គលដែលប្រព្រឹត្តកំហុស មិនអាចកាត់ទោសប្រទេសទេ ដែលចម្លើយនេះហាក់ដូចជាធ្វើឲ្យអ្នកចូលរួម៣-៤នាក់ មិនសូវសប្បាយចិត្ត ។

## ១) ការរំឭកនិងគោរពដល់ក្រុមជនជាតិភាគតិច

ដោយសម្រាកបន្តិចពីការធ្វើបទបង្ហាញនិងពិភាក្សាពីអំពើប្រល័យពូជសាសន៍ លោក អេនឌ្រូ ខេលី, លោក ឆាំង យុ និង តំណាងរបស់លោកជំទាវ ជា លាង បានជូនផ្ទាំងចំណារដល់តំណាងក្រុមជនជាតិភាគតិចដែលចូលរួមក្នុងកម្មវិធីប្រជុំ ។ នេះជាឱកាសមួយប្រកបដោយភាពឧឡារិកនិងមានអត្ថន័យបំផុតសម្រាប់អ្នកចូលរួម ។

ខ្លឹមសារដែលបង្កប់នៅក្នុងផ្ទាំងចំណារសម្រាប់ក្រុមទាំង៥រួមមាន ៖

### សម្រាប់ជនជាតិចាម ៖

«ចំណារនេះធ្វើឡើងដើម្បីរំឭកនូវការឈឺចាប់និងការសម្លាប់របស់ជនជាតិចាមនៅក្នុងប្រទេសកម្ពុជាអំឡុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។ ចំណារនេះក៏បង្ហាញឲ្យឃើញនូវសេចក្តីសង្ឃឹមដ៏ស្ងប់ស្ងាត់និងកំណត់ ថាយុត្តិធម៌នឹងកើតមានឡើង ហើយហេតុការណ៍ទាំងឡាយពីអតីតកាលនឹងមិនកើតឡើងជាថ្មីម្តងទៀតទេ ទោះបីជានៅកន្លែងណាក៏ដោយ ។ សម្រាប់អ្នកដែលអានចំណារនេះនៅពេលអនាគតនឹងមិនបំភ្លេចនូវអ្វីដែលបានកើតឡើងចំពោះជនជាតិឡើយ ។ សូមសម្តែងនូវការគោរពនិងរាប់អានគ្នាទៅវិញទៅមកជារៀងរាល់ថ្ងៃ ក្នុងជីវិតរស់នៅរបស់អ្នក» ។

អំពើប្រល័យពូជសាសន៍ ៖ ការពិត ការចងចាំ និងយុត្តិធម៌ ។ ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### សម្រាប់ជនជាតិភាគតិចតំបន់ភ្នំ ៖

«ចំណារនេះរំឭកឡើងវិញប្រកបដោយក្តីស្រឡាញ់និងមេត្តាករុណានូវសមាជិកជនជាតិភាគតិចទាំងឡាយ នៅក្នុងប្រទេសកម្ពុជាដែលបានទទួលរងទារុណកម្មនិងស្លាប់បាត់បង់ជីវិតក្នុងអំឡុងឆ្នាំ១៩៧៥ ដល់

ឆ្នាំ១៩៧៩ ។ សូមចងចាំថា ទោះបីជាយើងមានភាពខុសគ្នាក៏ដោយ ចំណងរួមជាមូលដ្ឋានរបស់មនុស្ស គឺ យើងរស់នៅក្នុងភពដ៏តូចមួយនេះជាមួយគ្នា ។ យើងដកដង្ហើមដោយប្រើខ្យល់តែមួយប្រភេទ ។ យើងទាំងអស់គ្នាឲ្យតម្លៃទៅលើអនាគតកូនចៅរបស់យើង ។ យើងទាំងអស់គ្នាមិនមែនអមតទេ ។

អំពើប្រល័យពូជសាសន៍ ៖ ការពិត ការចងចាំ និងយុត្តិធម៌ ។ ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

អេនថូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## សម្រាប់ព្រះសង្ឃ ៖

«ក្នុងការចងចាំព្រះសង្ឃប្រកបដោយសេចក្តីគោរព ដែលបានសុគតនិងទទួលរងដោយសារជំនឿនៅក្នុងប្រទេសកម្ពុជា អំឡុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។ យកឈ្នះកំហឹងដោយក្តីស្រឡាញ់ យកឈ្នះកំហុសដោយធ្វើអំពើល្អ យកឈ្នះមនុស្សចិត្តអាក្រក់ដោយស្មារតីសប្បុរស និងយកឈ្នះមនុស្សកុហកដោយការពិត» ។

អំពើប្រល័យពូជសាសន៍ ៖ ការពិត ការចងចាំ និងយុត្តិធម៌ ។ ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

អេនថូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## សម្រាប់បព្វជិត ៖

«ការរំឭកឡើងវិញនូវជីវិតនិងជំនឿរបស់បព្វជិត ដែលត្រូវបានសម្លាប់និងស៊ូទ្រាំនឹងការលំបាកក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។ សេចក្តីស្រឡាញ់និងមេត្តាករុណា ជាភាពចាំបាច់របស់យើង មិនមែនភាពល្អប្រណីតនោះទេ ។ ប្រសិនបើគ្មានសេចក្តីស្រឡាញ់និងមេត្តាករុណាទេនោះ មនុស្សជាតិមិនអាចរស់រានបានឡើយ« ។

អំពើប្រល័យពូជសាសន៍ ៖ ការពិត ការចងចាំ និងយុត្តិធម៌ ។ ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

អេនថូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### សម្រាប់ជនជាតិភាគតិចវៀតណាម ៖

«សម្រាប់ជនជាតិភាគតិចវៀតណាមដែលត្រូវបានសម្លាប់និងធ្វើទុក្ខបុកម្នេញដោយខ្មែរក្រហម សូមឲ្យយុត្តិធម៌កើតមានឡើងចំពោះអ្នកដែលបានទទួលរងនិងស្លាប់បាត់បង់ជីវិត ហើយសូមឲ្យព្រលឹងរបស់អ្នកដែលបានចែកឋាន ទៅកាន់សុគតិភព» ។

អំពើប្រល័យពូជសាសន៍ ៖ ការពិត ការចងចាំ និងយុត្តិធម៌ ។ ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅពេលដែលចំណារចុងក្រោយ (ដែលមានបន្តប់ទាំងអក្សរខ្មែរនិងអង់គ្លេស) ត្រូវបានប្រគល់ជូនដល់តំណាងអ្នកចូលរួម លោក ឆាំង យុ បានលើកផ្ទាំងរូបថតរបស់អ្នកគ្រូ ខុន សាវិន ឡើងលើ ហើយប្រគល់ឲ្យលោក អេនឌ្រូ ។ បន្ទាប់មក លោក អេនឌ្រូ បានជូនរូបថតនេះទៅអ្នកគ្រូ សាវិន ដោយសួរគាត់ថា តើគាត់នៅចងចាំការប្រជុំនៅឃុំរំលេចកាលពីខែមិថុនាកន្លងទៅដែរឬអត់ ។ លោកអេនឌ្រូ និយាយថា អ្នកគ្រូបានប្រាប់គាត់អំពីសាច់រឿងរបស់ឪពុកខ្លួនដែលបានលះបង់ជីវិតដើម្បីជួយស្រោចស្រង់ជីវិតរបស់អ្នកគ្រូ ហើយថាគាត់មានការរំជើបរំជួលនៅពេលដែលឮរឿងនេះ ។ នៅពេលដែលគាត់បានឃើញរូបថតរបស់អ្នកគ្រូ សាវិន ដែលថតដោយ កញ្ញា ស្រ៊ុន រ៉ូសានី មកពីអង្គភាពឆ្ពោះទៅរកយុត្តិធម៌នៅអាស៊ី គាត់ចង់ពង្រីករូបនិងដាក់ស៊ុមជូនដល់អ្នកគ្រូ ។ អ្នកគ្រូ សាវិន ឈរក្បែរលោក អេនឌ្រូ ដែលកំពុងអានខ្លឹមសារដែលយកចេញពីគម្ពីរគួរអាន និងគម្ពីរសាសនាគ្រីស្តចាស់នៅខាងក្រោមរូបថត ៖ «អ្នកណាដែលសង្គ្រោះ ជីវិតមួយនេះចាត់ទុកថាអ្នកនោះបានសង្គ្រោះពិភពលោកទាំងមូល ។ អ្នកណាដែលបំផ្លាញជីវិតមួយហាក់ដូចជាអ្នកនោះបំផ្លាញពិភពលោកទាំងមូល» ។

### គ) អំពើប្រល័យពូជសាសន៍ក្នុងបរិបទវប្បធម៌

ការប្រជុំនេះបន្តជាមួយការធ្វើបទបង្ហាញរបស់វាគ្មិនបីនាក់ដែលនិយាយអំពីនិយមន័យប្រល័យពូជសាសន៍នៅក្នុងបរិបទច្បាប់និងអក្សរសាស្ត្រ ។ ដំបូង លោកសាស្ត្រាចារ្យ ជួរ គារី ប្រធាននាយកដ្ឋានខេមរនីយកម្ម វចនានុក្រម និងបកប្រែ នៅរាជបណ្ឌិតសភាកម្ពុជា ពិភាក្សានិយមន័យអំពើប្រល័យ

ពូជសាសន៍នៅក្នុងបរិបទអក្សរសាស្ត្រនិងវប្បធម៌ ។ គាត់បានពន្យល់ថា ការពិតពាក្យប្រល័យពូជសាសន៍តាមអក្សរសាស្ត្រខ្មែររួមមានធាតុផ្សំបីខុសៗគ្នាគឺពាក្យ «ប្រល័យ» «ពូជ» និង «សាសន៍» និង «វប្បធម៌ជាមូលដ្ឋានរបស់មនុស្ស» ។ លោកសាស្ត្រចារ្យបានសង្ខេបពាក្យនេះដោយនិយាយថា អំពើប្រល័យពូជសាសន៍គឺជាអំពើបំផ្លិចបំផ្លាញក្រុមជាក់លាក់ណាមួយ ទោះបីជាក្រុមនោះមានវប្បធម៌ដូចគ្នាឬខុសគ្នា ។

លោក ស៊ីវ ធួន ជាវាគ្មិនទី២ និងជាគ្រូបង្រៀនថ្នាក់ជាតិក្នុងគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានពិភាក្សាពាក្យទាំងពីរនេះ ដោយភ្ជាប់ជាមួយពាក្យខ្មែរក្រហមមានដូចជា ពាក្យ «ការសម្លាប់បំផុតពូជ» និង «ដកទាំងឫស» ។ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា ខ្មែរក្រហមជឿថា ពួកគេត្រូវតែបំផ្លាញក្រុមឬដឹកទាំងឫសនូវក្រុមជាក់លាក់ទាំងនេះ ។ គាត់បានបញ្ជាក់ថា ខ្មែរក្រហមមិនបានជ្រើសរើសដោយផ្អែកលើអ្វីដែលពួកគេគិតថា ជាក្រុមដែលត្រូវតែបំផ្លាញចោល ពួកគេស្វះស្វែងបំផ្លាញក្រុមគ្រួសារ ជាតិសាសន៍ និងសមាជិកក្រុមទាំងស្រុង ដែលជាក្រុមងាយស្រួលធ្វើការកំណត់អត្តសញ្ញាណតាមរយៈរបៀបរបបនៃការរស់នៅនិងវប្បធម៌របស់ពួកគេ ។

វាគ្មិនទី៣ដែលត្រូវនិយាយគឺ លោក អេង កុកថាយ នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ គាត់បានលើកឡើងថា គាត់យល់ស្របនឹងការបកស្រាយនិយមន័យប្រល័យពូជសាសន៍តាមអក្សរសាស្ត្រខ្មែរ ហើយចង់ភ្ជាប់និយមន័យនោះទៅនឹងវិទ្យាសាស្ត្រសង្គម ។ ដោយប្រើអត្ថបទរបស់លោកសាស្ត្រចារ្យផ្នែកសិទ្ធិមនុស្សដ៏ល្បីល្បាញ គឺលោក វីលៀម សាបាស់ ធ្វើជាមូលដ្ឋាន លោក កុកថាយ បានពិនិត្យមើលពីទំនាក់ទំនងរវាងទស្សនៈស្តីពីអំពើប្រល័យពូជសាសន៍តាមទស្សនៈវិជ្ជា ច្បាប់ និងសង្គមវិទ្យា ។

គួរបញ្ជាក់ថា ការបកស្រាយពីនិយមន័យប្រល័យពូជសាសន៍របស់វាគ្មិនទាំងបីខាងលើនេះមានភាពខុសគ្នាបន្តិចពីការបកស្រាយតាមផ្លូវច្បាប់របស់លោក អេឌ្រូ សហព្រះរាជអាជ្ញាអន្តរជាតិ ។ លោក អេនឌ្រូ បានសង្កត់ធ្ងន់ថា អំពើប្រល័យពូជសាសន៍គឺជាចេតនាសម្លាប់សមាជិករបស់ ជាតិ ពូជសាសន៍ ជាតិពន្ធុ និងសាសនា ទាំងស្រុងឬដោយផ្នែក ហើយថាដូចជាក្នុងករណីសំណុំរឿង០០២ ខ្មែរក្រហមត្រូវបានរកឃើញថា មានចេតនាបំបាត់ពូជសាសន៍ចាមនិងវៀតណាម ។ បើតាមការបកស្រាយរបស់លោកសាស្ត្រាចារ្យ ដួរ គារី និង ស៊ីវ ធួន វិញ ឃើញថា ខ្មែរក្រហមប្រព្រឹត្តអំពើប្រល័យ

ពូជសាសន៍លើជនជាតិទាំងអស់ដែលរស់នៅក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ។ ប៉ុន្តែលោកសាស្រ្តាចារ្យទាំងពីរក៏ទទួលស្គាល់ថា ការបកស្រាយនេះវាទូលំទូលាយ ហើយ ថាទាក់ទងនឹងទោសទណ្ឌនិង ការចោទប្រកាន់គឺអាស្រ័យលើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងច្បាប់ជាអ្នកកំណត់ ។

នៅពេលវាគ្មិនទាំងបីនាក់បញ្ចប់ការធ្វើបទបង្ហាញរបស់ខ្លួន កញ្ញា ហ្វារីណា បានអនុញ្ញាតឲ្យមានការសួរសំណួរ ។ ស្រ្តីម្នាក់ដែលមកពីខេត្តមណ្ឌលគិរីបានសួរអំពីដំណើរការនៃការសងសំណងដែលដាក់ចេញដោយតុលាការ ។ សំណួររបស់គាត់បានជំរុញឲ្យបុរសចាមម្នាក់ទៀតមកពីខេត្តព្រះសីហនុសួរសំណួរដែរ ។ អ្នកចូលរួមអន្ទះសាចង់ដឹងអំពីមូលនិធិនៃការសងសំណង ព្រមទាំងទំនាក់ទំនងរវាងសំណង និងការដាក់ទោសដែលកំណត់ដោយតុលាការ ។

## ៨) អាហារថ្ងៃត្រង់របស់អ្នកចូលរួម

ការប្រជុំនេះបានសម្រាកសម្រាប់អាហារថ្ងៃត្រង់និងការថ្វាយបង្គំរបស់ជនជាតិចាម ។ អ្នកចូលរួមមានឱកាសអង្គុយពិសាអាហារតាមបែបប្រពៃណីរួមគ្នា ។ នៅឯតុអាហារ អ្នកចូលរួមអង្គុយចម្រុះគ្នា ដែលក្នុងនោះភ្ញៀវអន្តរជាតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអង្គុយពិសាអាហារជាមួយស្រ្តីចាមមកពីខេត្តពោធិសាត់ ហើយខ្មែរកម្ពុជាក្រោមអង្គុយពិសាជាមួយអ្នកចូលរួមដែលជនជាតិភាគតិចតំបន់ភ្នំ ។

## ៩) ការប្រជុំពេលរសៀល ការបញ្ចាំងខ្សែភាពយន្តរឿង "ឃ្លាតទៅសែនឆ្ងាយ!" គម្រោងប្រវត្តិសាស្រ្តតាមរយៈការសួរនាំក្នុងសហគមន៍ចាម និង សុន្ទរកថារបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ក) ការសន្ទនាអំពីខ្សែភាពយន្តនិងគម្រោងប្រវត្តិសាស្រ្ត

នៅពេលជួបប្រជុំឡើងវិញ ក្រុមអ្នកចូលរួមបានទស្សនាខ្សែភាពយន្ត ដែលផលិតដោយលោក ឆាយ បូរ៉ា មានចំណងជើងថា "ឃ្លាតទៅសែនឆ្ងាយ" ដែលរឿងនេះបង្ហាញជូនដោយផលិតករផ្ទាល់ ។ បន្ទាប់ពីរឿងរ៉ាវដ៏គួរឲ្យព្រឺព្រួចដែលនិយាយពីការបាត់បង់សមាជិកគ្រួសារនិងការរស់រានមានជីវិតពីរបប នោះ ខ្សែភាពយន្តរបស់លោក ឆាយ បូរ៉ា រៀបរាប់ពីបទពិសោធន៍ដ៏ជូរចត់របស់ម្តាយក្មេកគាត់ក្រោមរបបខ្មែរក្រហម ។

នៅដើមរឿង ខ្សែភាពយន្តនេះបានទាញការចាប់អារម្មណ៍ទស្សនិកជនយ៉ាងខ្លាំង ។ បុរសក៏ដូចជាស្ត្រីដែរបានឈ្ងោកទៅខាងមុខ ដែលនេះស្តែងឲ្យឃើញពីភាពប្រុងប្រយ័ត្នកុំឲ្យបាត់ពាក្យពេជន៍ ឬសកម្មភាពណាមួយរបស់ខ្សែរឿង ។ ទស្សនិកជនមានប្រតិកម្មតបរាល់ឃុតឆាកនីមួយៗ ដែលឃុតឆាកខ្លះត្រូវនឹងសាច់រឿងរបស់ពួកគាត់ដែរ ។ ជាពិសេស នៅក្នុងឃុតដែលពាក់ព័ន្ធនឹងការស្លាប់ ឬការនិរាសព្រាត់ប្រាស់កូនចេញពីឪពុកម្តាយ ទស្សនិកជនភាគច្រើនបានជូតទឹកភ្នែក ខណៈដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារ បានដើរចុះឡើងក្នុងបន្ទប់ប្រជុំ ដើម្បីផ្តល់ជំនួយចាំបាច់ ។

នៅពេលការបញ្ចាំងចប់ កញ្ញា ហ្វារីណា បាននិយាយទៅកាន់អ្នកចូលរួមទាំងនោះ ។ ដោយទទួលស្គាល់ថាខ្សែភាពយន្តនេះបានបង្ហាញពីបទពិសោធន៍ដ៏លំបាកជាច្រើន កញ្ញា ហ្វារីណា បានស្នើឲ្យអ្នកចូលរួមធ្វើការសម្រាកមួយរយៈដើម្បីធ្វើឲ្យអារម្មណ៍បានធូរស្រាលបន្តិច ។ ទោះបីជាមានភាពរំជើបរំជួលនិងលំបាកតាំងអារម្មណ៍ពីសំណាក់អ្នកចូលរួមយ៉ាងណាក៏ដោយ ខ្សែភាពយន្តនេះបានបម្រើឲ្យគោលបំណងសំខាន់មួយចំនួន ។ ទី១ ខ្សែភាពយន្តនេះនាំមកនូវការពិភាក្សាទៅលើអំពើប្រល័យពូជសាសន៍ដោយផ្សារភ្ជាប់ជាមួយសាច់រឿងរបស់បុគ្គលម្នាក់ៗ ដែលនេះជួយឲ្យមានការយល់ដឹងទៅលើអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិកាន់តែច្បាស់និងទូលំទូលាយជាងមុន ។ ខ្សែភាពយន្តនេះក៏ជួយឲ្យអ្នកចូលរួមមួយចំនួនមានការធូរស្រាលផងដែរ ។ ចុងក្រោយ ខ្សែភាពយន្តនេះក៏បង្កើតឱកាសផ្សេងៗសម្រាប់ទស្សនិកជន ដើម្បីស្គាល់គ្នានិងបន្តការទាក់ទងជាមួយគ្នា ។ អ្នកចូលរួមមួយចំនួនជួយលួងលោមបបោសអង្អែលថ្នមៗអ្នកអង្គុយនៅក្បែរខាងរបស់ពួកគេ នៅពេលដែលពួកគេយំឬសំឡឹងគ្នាទៅវិញទៅមកដោយការយល់ចិត្ត ។

**ខាងក្រោមនេះគឺជាប្រតិកម្មនិងយោបល់ផ្សេងពីអ្នកចូលរួមទៅលើខ្សែភាពយន្តនិងការប្រជុំទាំងមូល ៖**

### ១) ឡាច ត្រី

ខ្ញុំឈ្មោះ ឡាច ត្រី ដែលជាប្អូនប្រុសរបស់ ឡាច នី រស់នៅភូមិពោធិចិនដាំ ឃុំពោធិចិនដាំ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ។ ខ្ញុំយល់ស្របជាមួយនឹងខ្សែភាពយន្តឯកសារនេះពីព្រោះវាស្រដៀងគ្នាជាមួយបទពិសោធន៍របស់ខ្ញុំក្រោមរបបខ្មែរក្រហម ។ នៅក្នុងខ្សែភាពយន្ត តួឯកស្រីស្ទើរតែបាត់បង់សមាជិកគ្រួសាររបស់គាត់ទាំងអស់ ។ មានតែខ្លួនគាត់និងកូនពីរនាក់ប៉ុណ្ណោះដែលអាចវិលត្រឡប់មក

ស្រុកកំណើតនៅភ្នំពេញវិញ ។ ចំណែកខ្ញុំ ខ្ញុំបាត់បង់សមាជិកគ្រួសារ១៧នាក់នៅក្រោមរបបខ្មែរក្រហម ។ សូមអរគុណ ។

**២) ម៉ាត់ ហ៊ីម**

ខ្ញុំសូមគោរពដល់លោក ឆាយ បូរ៉ា និង អ្នកចូលរួមទាំងអស់ ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកឧបត្ថម្ភការប្រជុំនេះ ។ ខ្ញុំឈ្មោះ ម៉ាត់ ហ៊ីម មកពីឃុំត្រពាំងរពៅ ស្រុកកំពង់ត្រាច ខេត្តកំពត ។ ខ្ញុំសូមអរគុណយ៉ាងខ្លាំងដល់ខ្សែភាពយន្តនេះ ពីព្រោះវាជួយរំឭកយើងទាំងអស់គ្នាអំពីរបបខ្មែរក្រហម ដែលហាក់ដូចជានៅថ្មីៗ ។ វាក៏ជាវិធីមួយដើម្បីទប់ស្កាត់អំពីឧក្រិដ្ឋមិនឲ្យកើតឡើងសាជាថ្មីទៀត ។ ដូចដែលលោក បូរ៉ា បកស្រាយម្តងហើយថា គាត់មិនអាចបញ្ចូលអ្វីៗទាំងអស់ទៅក្នុងខ្សែភាពយន្តនេះ ទេដោយសារតែថវិកានិងពេលវេលាមានកម្រិត ។

ខ្ញុំសូមសួរពីរសំណួរ ។ ទី១ តើទឹកជ្រោះនៅក្នុងខ្សែភាពយន្តនេះថតនៅកន្លែងណា? ទី២ ទោះបីជាខ្ញុំបានរៀនសូត្រពីលោកសហព្រះរាជអាជ្ញានិងអ្នកជំនាញអក្សរសាស្ត្រខ្មែរកាលពីពេលព្រឹកមិញទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ប៉ុន្តែខ្ញុំនៅតែឆ្ងល់ ។ ការពិត អំពើប្រល័យពូជសាសន៍បានកើតឡើងរវាងឆ្នាំ១៩៣៣ ដល់ ឆ្នាំ១៩៤៥ ហើយអនុសញ្ញាប្រល័យពូជសាសន៍ត្រូវបានអនុម័តនៅឆ្នាំ១៩៤៨ ។ ខ្ញុំឆ្ងល់ថា តើប្រទេសកម្ពុជាក្លាយជាសមាជិកអនុសញ្ញានោះដែរឬទេនៅពេលនោះ? ហើយប្រសិនបើជាសមាជិក ហេតុអ្វីបានជាអង្គការសហប្រជាជាតិមិនអាចជួយទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា?

**បូរ៉ា :**

សូមអរគុណចំពោះសំណួររបស់លោក ។ ខ្ញុំសូមបកស្រាយសំណួរទី១ ។ ទីតាំងទឹកជ្រោះនេះថតនៅភ្នំបូង ខេត្តកោះកុង ។ យើងមានការលំបាកណាស់ក្នុងការថតទីតាំងនេះពីព្រោះវាត្រូវបានលក់ទៅឲ្យក្រុមហ៊ុនឯកជន ។ ទោះបីជាយ៉ាងណាក៏ដោយ យើងបានព្យាយាមអស់ពីសមត្ថភាពដើម្បីថតយកទឹកជ្រោះនោះ ។

**៣) រីម មូសា :**

ខ្ញុំឈ្មោះ រីម មូសា មកពីភូមិឃុំព្រែកទួល ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។ ខ្ញុំមកចូលរួមកម្មវិធីប្រជុំជាមួយម្តាយខ្ញុំ [ដែលយំខ្សឹកខ្សួលនៅពេលតាមដានខ្សែភាពយន្តរបស់លោក] ។ ខ្ញុំសូម ហៅលោកថា "បង" ដើម្បីឲ្យកាន់តែជិតស្និទ្ធ ។ នៅពេលដែលបងផលិតខ្សែភាពយន្តនេះឡើង ហាក់ដូចជាបងបានសហការជាមួយខ្ញុំអ៊ីចឹង [សើច] ។ ចំណុចដែលដូចគ្នានឹងរឿងរបស់ខ្ញុំខ្លាំងជាងគេគឺនៅត្រង់ឈុតមួយដែលម្តាយរបស់ខ្ញុំវាយខ្ញុំជាមួយនឹងមែកដំឡូងប្រហែល៧ដើម នៅពេលដែលមេកងរបស់ខ្ញុំហៅខ្ញុំឲ្យវិលត្រឡប់ទៅកងកុមារវិញ ។ ខ្ញុំទទួលស្គាល់ថា ខ្សែភាពយន្តនេះមិនដូចសាច់រឿងផ្ទាល់របស់យើងទាំងស្រុងទេ ដោយសារការកែសម្រួលខ្លះៗ ។ ប៉ុន្តែវាបានធ្វើឲ្យយើងចងចាំឡើងវិញ ។ នេះគឺជាការពិត ។

ខ្ញុំសូមថ្លែងអំណរគុណដល់បង បូវ៉ា ដែលបានខិតខំប្រឹងប្រែងផលិតកុននេះឡើង ។ ប្រសិនបើបងផលិតខ្សែភាពយន្តលើកក្រោយទៀត ខ្ញុំស្ម័គ្រចិត្តដើរតួដើម្បីបង្ហាញពីអារម្មណ៍រំដើបរំជួលផ្សេងគ្នា [ស្នូរទះដៃ] និងថាតើជនជាតិចាមបានតស៊ូយ៉ាងដូចម្តេចដើម្បីរស់ ដោយផ្សារភ្ជាប់ជាមួយសាសនា វប្បធម៌ និងអាហារ ។ល ។ សូមឲ្យបង លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសហការីមានសុខភាពល្អ និងទទួលជោគជ័យគ្រប់ភារកិច្ច ។

**បូវ៉ា :**

សូមអរគុណ មូសា ។ ខ្ញុំសូមជម្រាបថា ខ្ញុំមានគម្រោងផលិតខ្សែភាពយន្តមួយទៀតស្តីពីជនភៀសខ្លួនខ្មែរនៅតាមព្រំដែនកម្ពុជា-ថៃ នៅក្រោយនិងក្នុងអំឡុងរបបខ្មែរក្រហម ដើម្បីថតយកការរស់នៅក្រោមវាលពិឃាតមួយទៅវាលពិឃាតមួយ ។ នៅពេលខ្ញុំបានមើលខ្សែភាពយន្តដែលផលិតឡើងដោយជនជាតិញូហ្ស៊ីឡង់អំពីក្រុមគ្រួសារខ្មែរដែលរស់នៅតាមបណ្តោយព្រំដែន វាប៉ះពាល់ដល់អារម្មណ៍របស់ខ្ញុំជាខ្លាំង ។ ក្រុមគ្រួសារនោះមានបំណងស្វះស្វែងរកការជួយពីអង្គការសហប្រជាជាតិ ប៉ុន្តែជាជំនួសមកវិញ ពួកគេទទួលរងបទពិសោធន៍ដ៏ជូរចត់ ។ បុរសដែលជាមេគ្រួសារត្រូវបានប្រាប់ថាគាត់នឹងត្រូវបញ្ជូនទៅប្រទេសទី៣ ប៉ុន្តែនៅពេលគាត់ទៅដល់ព្រំដែន គាត់បែរជាស្ថិតក្នុងភាពងងឹតនៅពេលគាត់បើកបង្អួចឡើង ។ ជោគវាសនារបស់ក្រុមគ្រួសារនោះបញ្ចប់ដោយភាពជូរចត់ ។

ខ្សែភាពយន្តថ្មីនេះមិនជំរុញឲ្យមានការសងសឹកឬជំរុញឲ្យមានការយល់ឃើញជាអវិជ្ជមានទៅលើប្រទេស ជិតខាងឡើយ ដោយសារតែនៅទីនោះក៏មានមនុស្សល្អជាច្រើនដែរ ។

សម្រាប់រូបខ្ញុំ នៅពេលដែលអ្នកសារព័ត៌មានសួរខ្ញុំថាតើខ្ញុំខឹងនឹងអៀង សារី ដែរឬអត់ ខ្ញុំឆ្លើយថា "បាទ" ប៉ុន្តែខ្ញុំមិនចង់សងសឹកទេ ដោយសារតែហេតុការណ៍ទាំងឡាយបានកើតឡើងជាង៣០ឆ្នាំមកហើយ ។ ខ្ញុំគិតថា វាល្មមគ្រប់គ្រាន់សម្រាប់ជនជាតិខ្មែរដែលត្រូវបញ្ឈប់ការចងគំនុំនិងសម្លាប់គ្នាទៀតហើយ ។

**៤) ពៅ ស៊ីនួន :**

ខ្ញុំមកពីឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ ។ ខ្ញុំរំភើបនិងរំជួលចិត្តនៅពេល ដែលបានទស្សនាខ្សែភាពយន្តនេះ ។ ខ្ញុំក៏ដូចជាអ្នកចូលរួមផ្សេងទៀតដែរ សូមថ្លែងអំណរគុណដល់ការខិតខំប្រឹងប្រែងក្នុងការផលិតរឿងនេះឡើង ។ ខ្ញុំមិនដែលឃើញខ្សែភាពយន្តណាដែលវែង លើកលែងតែខ្សែវីដេអូខ្លីៗស្តីអំពីជីវិតរស់នៅប្រចាំថ្ងៃ ក្រោមរបបខ្មែរក្រហមចាប់តាំងពីរបបនេះដួលរលំ ។

ខ្ញុំសូមសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើយ៉ាងណាចាក់ផ្សាយខ្សែភាពយន្តនេះតាមកញ្ចក់ទូរទស្សន៍ ឲ្យបាន២ដងក្នុងមួយឆ្នាំដើម្បីរំឭកនិងបង្រៀនក្មេងជំនាន់ក្រោយឲ្យដឹងពីការឈឺចាប់ ដើម្បីឲ្យពួកគេចេះជួយអភិវឌ្ឍន៍ប្រទេសជាតិ ។ ចុងក្រោយ ខ្ញុំសូមប្រសិទ្ធិពរដល់អ្នកចូលរួមនិងអ្នករៀបចំកម្មវិធីឲ្យជួបប្រទះតែសេចក្តីសុខនិងជោគជ័យនៅគ្រប់ការងារទាំងអស់ ។

**៥) ឡាច ស៊ីថា :**

ខ្ញុំមកពីឃុំដាក់ដាម ស្រុកអូររាំង ខេត្តមណ្ឌលគិរី ។ សូមអភ័យទោសឲ្យខ្ញុំផងប្រសិនបើមានកំហុសខុសឆ្គង ។ ខ្ញុំចាប់អារម្មណ៍ទៅលើខ្សែភាពយន្តយ៉ាងខ្លាំង ព្រោះវាជាការពិត ។ យើងខ្វះខាតសព្វបែបយ៉ាងតាំងពីទ្រនាប់ជើងនិងម្ហូបអាហារនៅក្រោមរបបខ្មែរក្រហម ។ នៅពេលយើងប្រាប់ក្មេងជំនាន់ក្រោយអំពីការឈឺចាប់របស់យើង ពួកវាមិនជឿ ។ ពួកគេសួរយើងថា "ប្រសិនបើរបបខ្មែរក្រហមលំបាកអ៊ីចឹង ហេតុអ្វីបានជាយើងមិនរត់?" ខ្សែភាពយន្តនេះជួយរំឭកឡើងវិញនិងអប់រំពួកគេពីការឈឺចាប់របស់យើង ។

**បូរ៉ា :**

ខ្ញុំនឹងព្យាយាមបំពេញតាមសំណូមពររបស់បងៗ [ប្រាប់តាមត្រង់ទៅចុះ] ខ្ញុំក៏ជួបប្រទះដូចជាបងៗដែរ ។ ខ្ញុំឈឺចាប់យ៉ាងខ្លាំងនៅពេលពួកគេ [កូនសិស្សរបស់ខ្ញុំនិងក្មេងជំនាន់ក្រោយ] មិនជឿការឈឺចាប់របស់យើងនៅពេលយើងនិយាយប្រាប់វា ។ មន្ត្រីមាក់ដែលជាមិត្តភ័ក្តិរបស់ខ្ញុំបារម្ភជំនួសខ្ញុំ ក្រែងលោខ្សែភាពយន្តនេះមិនអាចទាក់ទាញក្មេងជំនាន់ក្រោយ ដោយសារពួកគេចាប់អារម្មណ៍ខ្សែភាពយន្តផ្សេងទៀត ដូចជា រឿងខ្មោច ឬ រឿងស្នេហាច្រើនជាង ។ ទោះបីយ៉ាងនេះក៏ដោយ ប្រសិនបើយើងដកថយ យើងនឹងបរាជ័យ ។ យើងគួរតែបន្តអប់រំក្មេងជំនាន់ក្រោយ ។ ដូចបង យុ [ឆាំង យុ] បានលើកឡើងថា ប្រសិនបើយើងភ្លេចប្រវត្តិសាស្ត្ររបស់យើង ហាក់ដូចជាយើងសម្លាប់អត្តសញ្ញាណជាតិរបស់យើង ។ ដូចជានៅប្រទេសអាល្លឺម៉ង់ ប្រជាជនរបស់គេត្រូវបានជំរុញឲ្យនិយាយអំពីហូឡូខូសន៍ ដើម្បីឲ្យដឹងពីការពិតឲ្យកាន់តែទូលំទូលាយ ហើយដើម្បីលើកកំពស់ការយល់ដឹងរបស់ក្មេងជំនាន់ក្រោយកុំឲ្យយកគំរូតាម ។ គ្មាននរណាដឹងទេថា តើក្មេងជំនាន់ក្រោយនឹងមិនប្រព្រឹត្តអំពើបែបនេះ ប្រសិនបើពួកគេក្លាយជាអ្នកដឹកនាំនៅពេលអនាគត ដោយសារតែពួកគេមិនដឹងពីផលវិបាកនិងមូលហេតុដែលនាំឲ្យកើតអំពើនេះ ។

ដូចជាលោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលើកឡើងអ៊ីចឹង យើងត្រូវតែយកឈ្នះឧបសគ្គទាំងឡាយ ។ ការនិយាយពីបទពិសោធន៍អតីតកាលមិនត្រឹមតែបម្រើឲ្យប្រវត្តិសាស្ត្រប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឲ្យក្មេងជំនាន់ក្រោយមានការអាណិតអាសូរចំពោះឪពុកម្តាយគេ ក្រុមគ្រួសារ និងមនុស្សជំនាន់មុនទាំងមូល ។ ខ្ញុំសុំទោស ខ្ញុំនិយាយច្រើនបន្តិចហើយ ។ ប្រសិនបើអ៊ំពូមីងមានសំណួរឬយោបល់អ្វី សូមសួរ ។

**៦) លី សារី ៖**

ខ្ញុំមកពីឃុំព្រៃឃ្មុំ ស្រុកកំពត ខេត្តកំពត ។ អ្នកចូលរួមមានសំណួរជាច្រើនអំពីខ្សែភាពយន្ត ដែលទាំងអស់នេះជារឿងពិត ។ នេះវាគ្រប់គ្រាន់ហើយ ។ ប្រសិនបើខ្សែភាពយន្តនេះកាន់តែឈឺចាប់ជាងនេះ ខ្ញុំប្រហែលជាមិនអាចទ្រាំមើលបានទេ ។ វាប្រហែលជាបង្កឲ្យអ្នកដែលមានជំងឺបេះដូងកាន់តែលំបាកថែមទៀត ។

*ខ្ញុំសូមចូលរួមក្នុងការពិភាក្សានេះ ។ តាមដែលខ្ញុំដឹង អង្គការសហប្រជាជាតិបានអនុម័តលើអនុសញ្ញាការពារអំពើប្រល័យពូជសាសន៍តាំងពីឆ្នាំ១៩៤៨ ប៉ុន្តែអង្គការសហប្រជាជាតិមិនជឿឬមិនចាប់អារម្មណ៍នឹងរឿងនេះ តើយើងចង់ឲ្យក្មេងជំនាន់ក្រោយជឿយ៉ាងម៉េចទៅ? វាលំបាកជឿណាស់ ។ ទោះបីយ៉ាងណាក៏ដោយ ខ្ញុំសង្កេតឃើញថា បន្ទាប់ពីអង្គការសហប្រជាជាតិដឹង ពួកគេចាប់អារម្មណ៍ជាងយើងទៅទៀត ហើយកំពុងធ្វើការយ៉ាងសកម្ម ។*

*និយាយដល់និយមន័យអំពើប្រល័យពូជសាសន៍ យើងបានរៀនសូត្រអំពីពាក្យនេះពីសហព្រះរាជអាជ្ញា និងអ្នកជំនាញអក្សរសាស្ត្រខ្មែរកាលពីពេលព្រឹកមិញ ។ តាមដែលខ្ញុំយល់ ពាក្យនេះមកពីបន្សំរវាង "ប្រល័យ+ពូជ+សាសន៍" មានន័យថា លុបបំបាត់ពូជដោយគ្មានគិតពិចារណា ។ ចុងក្រោយនេះ សូមឲ្យបង (បូរ៉ា) បន្តខិតខំប្រឹងប្រែងធ្វើយ៉ាងណាឲ្យប្រជាជនជឿថាមានអំពើប្រល័យពូជសាសន៍ ។ ខ្ញុំសូមស្ញើចសរសើរការខិតខំប្រឹងប្រែងរបស់បងយ៉ាងខ្លាំង ។*

**បូរ៉ា** :

*ខ្ញុំសូមអរគុណយ៉ាងខ្លាំងដល់វត្តមាននិងយោបល់របស់អ៊ំពូមីងទាំងអស់គ្នា ។ ខ្ញុំមិនដែលគិតថាយើងខុសគ្នានោះទេ ហើយមិនដែលចាត់ទុកថា បងប្អូនមូស្លីមខុសពីបងប្អូនខ្មែរឬជនជាតិដទៃឡើយ ។ ខ្ញុំសប្បាយរីករាយណាស់ដោយនេះជាលើកទី១ ហើយដែលខ្ញុំឈរនៅចំមុខអ៊ំពូមីងទាំងអស់គ្នាដែលជាអ្នកកាន់សាសនាអ៊ីស្លាមជាច្រើនរយនាក់ ។ អតីតកាលធ្វើឲ្យយើងឈឺចាប់ ហើយម្នាក់ៗមានមុខរបរចិញ្ចឹមជីវិត ប៉ុន្តែសូមកុំអស់សង្ឃឹម យើងត្រូវតែបន្តការខិតខំប្រឹងប្រែងតទៅទៀត ។*

*បន្ទាប់ពីបញ្ចប់ការពិភាក្សាទៅលើខ្សែភាពយន្តរួចមក កញ្ញា ហ្វារីណា បានជម្រាបជូនដោយសង្ខេបនូវគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំក្នុងសហគមន៍ចាម ដោយជំរុញឲ្យអ្នកចូលរួមចែករំលែកបទពិសោធន៍របស់ខ្លួន ។ ហ្វារីណា ក៏បានអនុញ្ញាតឲ្យមានការសួរសំណួរអំពីគម្រោងខ្សែភាពយន្ត និងសុំឲ្យមានការសន្ទនាអំពីបទពិសោធន៍នៅក្នុងការប្រជុំ ព្រមទាំងបន្តការសហការចងក្រងសាច់រឿងក្រោមរបបខ្មែរក្រហម ។ អ្នកចូលរួមទាំងអស់គ្នាបានបង្ហាញសំឡេងនិងកាយវិការយល់ព្រមនឹងការលើកឡើងរបស់ ហ្វារីណា ។ ជនជាតិចាមពីរនាក់បានសួរសំណួរទាក់ទងនឹងតួនាទីរបស់អង្គការសហប្រជាជាតិដែលបរាជ័យក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅឆ្នាំ១៩៧៨-៧៩ ។ លោកនាយកមជ្ឈមណ្ឌលឯកសារបានឆ្លើយតបទៅវិញ ប៉ុន្តែជំរុញឲ្យពួកគាត់សួរអគ្គលេខាធិការអង្គការសហប្រជាជាតិ*

លោក បាន គីមមួន ដែលនឹងមកធ្វើទស្សនកិច្ចនៅកម្ពុជានៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ដោយផ្ទាល់ ។

## ៥) ប្រសាសន៍របស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារ

លោក ឆាំង យុ បានសង្ខេបសុន្ទរកថារបស់លោកប្រកបដោយអត្ថន័យ ស្តីពីបុសគល់ដែលបណ្តាលឲ្យមានអំពើប្រល័យពូជសាសន៍និងវិធីទប់ស្កាត់អំពើនេះ ។ លោកបានបញ្ជាក់ថា ការរំលោភបំពានទាំងឡាយ ដូចជាការមិនគោរពភាពខុសគ្នានិងមិនចេះអត់ឱនឲ្យគ្នា អាចប៉ះពាល់ដល់ប្រជាធិបតេយ្យ ។ លោក បាននិយាយថា "ទោះបីជាយើងមានជំនឿដូចគ្នា ប៉ុន្តែយើងមិនដូចគ្នាបេះបិទទេ ទោះបីយ៉ាងណា ក៏យើងមិនខុសគ្នាដែរ ។ យើងទាំងអស់គ្នាចូលរួមចំណែកកសាងប្រជាធិបតេយ្យនៅក្នុងពិភពលោក" ។ លោកបានសង្កត់ធ្ងន់ថា "នេះជាប្រវត្តិសាស្ត្ររបស់យើង ។ សូមបន្តការសហការដើម្បីសម្រេចឲ្យបានគោលដៅ" ។

## ៦) ការវាយតម្លៃកម្មវិធីប្រជុំនិងបូកសរុបលទ្ធផល

មុនពេលចាកចេញពីបន្ទប់ប្រជុំ អ្នកចូលរួមបានបំពេញតារាងវាយតម្លៃកម្មវិធីប្រជុំ ។ ជាលទ្ធផល៩៧ភាគរយនៃអ្នកចូលរួមបានសរសេរថា ពួកគេពេញចិត្តនឹងការប្រជុំយ៉ាងខ្លាំង ហើយ៣ភាគរយទៀតសម្តែងការពេញចិត្តនឹងការប្រជុំ, ការរៀបចំនិងកិច្ចស្វាគមន៍រាក់ទាក់របស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកចូលរួមជាច្រើនបានស្នើសុំឲ្យមជ្ឈមណ្ឌលឯកសាររៀបចំកម្មវិធីបែបនេះ ធ្វើយ៉ាងណាឲ្យបានមួយឆ្នាំម្តង ដើម្បីរំឭកឡើងវិញនិងបង្កើនការយល់ដឹងទៅលើអំពើប្រល័យពូជសាសន៍ ។ តំណាងជនជាតិចាមមួយចំនួនបានប្រគល់រូបថតវិហារនិងស្ថិតិភូមិដល់ក្រុមការងារសម្រាប់ចុះផ្សាយក្នុងប្រព័ន្ធវេបសាយចាមដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

មជ្ឈមណ្ឌលឯកសារកម្ពុជាវាយតម្លៃកម្មវិធីប្រជុំផ្អែកលើតារាងវាយតម្លៃនេះ ការអង្កេតនិងការពិភាក្សានៅក្នុងការប្រជុំ ដើម្បីកំណត់ថាតើការប្រជុំនេះត្រូវតាមគោលដៅដែលចង់បានឬអត់ ។ ដោយផ្អែកលើភ័ស្តុតាងទាំងនេះ ការប្រជុំបានពង្រឹងការយល់ដឹងទៅលើអំពើប្រល័យពូជសាសន៍តាមផ្លូវច្បាប់និងសង្គមរបស់អ្នកចូលរួម ក៏ដូចជាតាមផ្លូវវប្បធម៌និងអក្សរសាស្ត្រ ។ ការប្រជុំនេះក៏ផ្តល់អត្ថប្រយោជន៍យ៉ាងខ្លាំងដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានធ្វើការកត់ត្រានូវសាច់រឿងរបស់អ្នកចូលរួម និងអ្វីដែលពួកគាត់គិតនិងរៀនសូត្រនៅក្នុងកម្មវិធីប្រជុំ ។ នេះជា

ឱកាសមួយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាអាចឆ្លើយតបនឹងសំណូមពររបស់អ៊ីម៉ាំខេត្ត ព្រះសីហនុ ហើយចូលរួមជាវិភាគទាននូវទឹកប្រាក់១៥០ដុល្លារ ដើម្បីជួសជុលវិហារអាល់មូខលីហ្វាស់ នៅភូមិ អូរសំអាត សង្កាត់៣ ខេត្តព្រះសីហនុ ហើយការចូលរួមចំណែកនេះអាចជួយថែរក្សាវប្បធម៌និង សាសនារបស់សហគមន៍ចាម ។

បើទោះបីជាការប្រជុំជួបប្រទះឧបសគ្គមួយចំនួន ដោយផ្អែកទៅលើលទ្ធផលខាងលើ មជ្ឈមណ្ឌល ឯកសារកម្ពុជាចាត់ទុកការប្រជុំលើកទី១ជាមួយជនជាតិភាគតិចស្តីពីការយល់ដឹងទៅលើអំពើប្រល័យ ពូជសាសន៍ជាជោគជ័យមួយ ។ មជ្ឈមណ្ឌលឯកសារនឹងរៀបចំការប្រជុំលើកទី២នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១០ ។

## សាច់រឿងខ្លីរបស់ ខុន សារិន

នៅក្នុងកិច្ចប្រជុំជាមួយអ្នកនៅរស់រានដែលជាខ្មែរក្រោមនៅខេត្តពោធិ៍សាត់ ខុន សារិន ដែលជាគ្រូបង្រៀននៅសាលាបឋមសិក្សាឃុំស្វាយដូនកែវ បានរំឭកពីការឈឺចាប់ដែលរស់នៅក្នុងឃុំ រំលេច កាលពីសម័យខ្មែរក្រហម ។ ទោះបីជារឿងរ៉ាវបានកើតឡើងអស់រយៈពេលជាងបីទសវត្សរ៍ មកហើយ សារិន ដែលបច្ចុប្បន្នមានអាយុជាង៤០ឆ្នាំបានរៀបរាប់ពីរឿងរ៉ាវរបស់គាត់នៅក្នុង កិច្ចប្រជុំជាមួយ អេនឌ្រូ ខេលី ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ។

រឿងរ៉ាវដែលគាត់មិនអាចបំភ្លេចបានគឺការស្លាប់របស់ឪពុកគាត់ដែលមានឈ្មោះថា ស៊ុយ ហុង ។ សារិន និងគ្រួសារត្រូវជម្លៀសទៅឃុំរំលេច នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅ ពាក់កណ្តាលឆ្នាំ១៩៧៥ ។ ប្រហែលជាមួយឆ្នាំបន្ទាប់ពីការជម្លៀស ម្តាយរបស់គាត់ដែលជា ខ្មែរក្រោមចាប់មានផ្ទៃពោះ និងមានសុខភាពខ្សោយជាលំដាប់ ។ ខ្មែរក្រហមបានចោទប្រកាន់ម្តាយ គាត់ថាពូកែឈឺ ដូច្នេះត្រូវតែសម្លាប់ចោល ។ សារិន នៅចាំបានថា នៅពេលដែលគាត់មានអាយុ៦ឆ្នាំ ខ្មែរក្រហមចង់សម្លាប់ខ្មែរក្រោមទាំងអស់គ្នា ពីព្រោះខ្មែរក្រោមត្រូវចោទប្រកាន់ថាមាន «ខ្លួនក្បាល វៀតណាម» ។ នៅថ្ងៃមួយ ម្តាយរបស់ សារិន ឈឺធ្ងន់ហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យ ។ ក្រោយមក គាត់ឮថា ម្តាយរបស់គាត់ត្រូវគេចាក់ទឹកបញ្ចូលហើយស្លាប់ភ្លាមមួយរំពេច ។ ហុង ដែលត្រូវជាឪពុក របស់ សារិន ត្រូវបានចោទប្រកាន់ថាបានស៊ីសាច់មនុស្ស ដូច្នេះ ខ្មែរក្រហមក៏សម្លាប់គាត់

*នៅឆ្នាំ១៩៧៧ ។ គាត់មិនមែនជាកូនកាត់ខ្មែរវៀតណាមឬកម្ពុជាក្រោមទេ ។ ម្តាយរបស់ សារិន ទើបជាខ្មែរក្រោម ។*

*នៅក្នុងរបបខ្មែរក្រហម ហុង ត្រូវអង្គការបញ្ជាឲ្យជីករណ្តៅនិងកប់សាកសព និងធ្វើការងារផ្សេងៗទៀត ។ ថ្ងៃមួយ គាត់ត្រូវបានបញ្ជាឲ្យទៅកប់សាកសពជាមួយនឹងបុរសពីរបីនាក់ ។ ដោយអស់កម្លាំងពេក នៅថ្ងៃនោះ គាត់មិនបានជីករណ្តៅឲ្យជ្រៅល្មមសម្រាប់កប់សាកសពទេ ។ ក្រោយមក ក៏មានឆ្កែព្រៃនិងសត្វផ្សេងៗទៀតស៊ីសាច់សាកសពនោះ ។ ដោយហេតុនេះ កម្មាភិបាលខ្មែរក្រហមក៏ចោទប្រកាន់ ហុង ថាបានស៊ីសាច់សាកសពទាំងនោះ ។ ដូច្នេះ កម្មាភិបាលខ្មែរក្រហមពីរនាក់ ដែលមានកាំបិតផ្អាក់នៅជាប់ខ្លួនបានមកបណ្តើរគាត់ទៅសម្លាប់ទាំងថ្ងៃ ។ នៅពេលដែលឃើញខ្មែរក្រហមបណ្តើរឪពុករបស់ខ្លួន សារិន ក៏ដើរតាមពីក្រោយ ។ នៅពេលនោះ ពូរបស់ សារិន ដែលជាអ្នកមូលដ្ឋានម្នាក់ និងមានឈ្មោះ ខន ក៏នៅទីនោះដែរ ។ ឃើញដូច្នោះ ឪពុករបស់ សារិន ក៏បានសុំឲ្យពូរបស់ សារិន ជួយស្រោចស្រង់ជីវិតកូនស្រីរបស់គាត់ផង ។ ពូរបស់ សារិន ក៏សន្យាថានឹងព្យាយាមអស់ពីសមត្ថភាពមិនឲ្យអ្នកណាធ្វើបាប សារិន ឡើយ ។*

*សារិន នៅចាំបានថានៅថ្ងៃមួយ គាត់ចង់ទៅជាមួយមនុស្សមួយក្រុមដែលត្រូវបានអង្គការហៅឲ្យទៅដាំពោត ប៉ុន្តែ ខន មិនបានអនុញ្ញាតឲ្យ សារិន ទៅជាមួយគេទេ ពីព្រោះគាត់ដឹងថាក្រុមនោះនឹងត្រូវគេបញ្ជូនទៅសម្លាប់ ។ នៅក្នុងរបបខ្មែរក្រហម ការបញ្ជាឲ្យមនុស្សម្នាក់ប្តូរពីកន្លែងមួយទៅកន្លែងមួយ ឬឲ្យទៅដាំដំណាំនៅកន្លែងផ្សេងគឺតែងតែមានន័យថា យកមនុស្សទៅសម្លាប់ ។*

*ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ សារិន ប្រើប្រាស់នាមត្រកូលរបស់ពូគាត់គឺ «ខន» ដោយសារ ខន បានជួយជីវិតរបស់គាត់ និងដើម្បីបង្ហាញពីការគោរពស្រឡាញ់ ។*

*ដោយសារតែនេះគឺជាការឈឺចាប់ សារិន មិនដែលភ្លេចនូវបទពិសោធន៍នេះទេ ។ វានៅដក់ជាប់ក្នុងចិត្តរបស់គាត់ដូចជារឿងនេះនៅថ្មីៗអ៊ីចឹង ។ គាត់បានរំឭកពីការស្លាប់របស់ឪពុកគាត់យ៉ាងច្បាស់ក្រឡែត ។ គាត់បាននិយាយថា «ទោះបីជានៅពេលនោះ ខ្ញុំគឺជាក្មេងក៏ដោយ ប៉ុន្តែខ្ញុំនៅចាំនូវអ្វីដែលបានកើតឡើងជាច្រើន រួមទាំងការរងទុក្ខវេទនា ។ វាហាក់ដូចជានៅថ្មីៗ» ។*

***អត្ថបទដោយ កញ្ញា សូ ហ្វារីណា ប្រធានគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំក្នុងសហគមន៍ចាម***